ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣ ✻ ៤៤

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ២៤៥០ ធទឧ

## សេចក្តីជូនដំណឹង

បន្ទាប់ពីបានធ្វើការតាមដានទៅលើស្ថានភាពទូទៅនៃអាកាសធាតុ ពិសេសការតាមដានទៅលើកម្រិតសីតុណ្ហភាព នៅលើផ្ទៃមហាសមុទ្រប៉ាស៊ីហ្វិកភាគខាងលិច និងផ្ទៃសមុទ្រចិនខាងត្បូង ( ដែលការប្រែប្រួលសីតុណ្ហភាព នៅតំបន់ទាំងពីរនេះ មានឥទ្ធិពលខ្លាំងមកលើស្ថានភាពអាកាសធាតុព្រះរាជាណាចក្រកម្ពុជា ) រួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជន ឱ្យបានជ្រាបព័ត៌មានដូចខាងក្រោម ៖

1- **មហាសមុទ្រប៉ាស៊ីហ្វិកភាគខាងលិច** ៖ ចាប់តាំងពីខែមីនា ឆ្នាំ 2015 មក កម្រិតសីតុណ្ហភាពនៅតំបន់មហាសមុទ្រប៉ាស៊ីហ្វិក មានការកើនឡើងពី 0,5-0,7 $^{\circ}C$ ហើយបើយោងទៅតាមការព្យាករ នៅក្នុងឆ្នាំ 2016 ខាងមុខនេះ វាមាននិន្នាការកើនឡើងបន្តិចថែមទៀត ។

2- **សមុទ្រចិនខាងត្បូង** ៖ យោងតាមការព្យាករ ចាប់ពីខែកុម្ភៈ ឆ្នាំ 2016 ទៅ កម្រិតសីតុណ្ហភាពមានការកើនឡើងពី 0,5-1$^{\circ}C$ ពោលគឺ កើនឡើងខ្ពស់ជាងដើមឆ្នាំ 2015 កន្លងទៅ ( ដើមឆ្នាំ 2015 កំណើនសីតុណ្ហភាព មានត្រឹមតែ 0,2-0,5$^{\circ}C$ ប៉ុណ្ណោះ ) ។

ការកើនឡើងនៃកម្រិតសីតុណ្ហភាព ដូចបានជម្រាបជូនខាងលើ អាចនឹងធ្វើឱ្យស្ថានភាពអាកាសធាតុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ( ចាប់ពីខែធ្នូ ឆ្នាំ 2015 ដល់ខែឧសភា ឆ្នាំ 2016 ) មានដូចខាងក្រោម ៖

- សម្រាប់រដូវប្រាំងឆ្នាំ 2016 នេះ ពិសេសក្នុងខែមេសា និងឧសភា អាកាសធាតុអាចនឹងមានសភាពក្តៅហួតហែង សីតុណ្ហភាពអតិបរមានឹងកើនដល់ 40-41$^{\circ}C$ ។
- រដូវវស្សាឆ្នាំ 2016 អាចនឹងមកដល់យឺត ហើយនៅដើមរដូវមានភ្លៀងធ្លាក់តិច ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជន ជ្រាបជាព័ត៌មាន និងសូមចូលរួមថែរក្សាទឹកទុកឱ្យបានល្អ សម្រាប់បម្រើដល់ការប្រើប្រាស់ប្រចាំថ្ងៃ ក៏ដូចជាសម្រាប់វិស័យកសិកម្ម ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៥*

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ ( ៨៥៥ ២៣.៧២៥ ៩៨៩ / ( ៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh